# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់នៅភ្នំពេញថ្មី
# ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨

*សុភមង្គលដ៏ពិតប្រាកដ*

អត្ថបទទី១៖ វិវ ៧,២-៤.៩-១៤
អត្ថបទទី២៖ ១យហ ៣,១-៣
ដំណឹងល្អ៖ មថ ៥,១-១២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ ត្រូវថ្ងៃដែលយើងគោរពសន្តបុគ្គលទាំងឡាយ។ យើងដឹងថាមានសន្តសន្តីយ៉ាងច្រើន ដែលនៅស្ថានបរមសុខកំពុងអធិដ្ឋាននៅក្នុងរបៀបពិសេស ដើម្បីចូលរួមជាមួយសម្លេងតូចតាចរបស់យើង ជាការអធិដ្ឋានរបស់យើងដើម្បីឲ្យសម្លេងនិងការអធិដ្ឋានរបស់យើងទៅដល់ព្រះជាម្ចាស់។ ព្រះនាងម៉ារីឥតបានឆ្លងបញ្ជីនៃព្រះសហាគមន៍ដែលត្រូវធ្វើការស៊ើបអង្កេត ដើម្បីក្លាយជាសន្តីបុគ្គល ព្រះនាងម៉ារីជាសាវ័ក ជាគ្រីស្តទូតមុនគេបង្អស់ ព្រះនាងម៉ារីជាមាតារបស់ព្រះជាម្ចាស់ ពីដើមរៀងមកធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ជានិច្ច។ ក្នុងអត្ថបទទីពីរ "**ព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យយើងធ្វើជាបុត្រធីតារបស់ព្រះអង្គ**" គោលដៅនៃជីវិតរបស់យើងគឺមើលឃើញព្រះជាម្ចាស់។ **ព្រះជាម្ចាស់ ជាព្រះដ៏វិសុទ្ធ** ព្រះនាងម៉ារីជាសន្តីមុនគេបង្អស់ដោយសារព្រះនាងម៉ារីភ្ជាប់ជាមួយព្រះជាម្ចាស់ អស់មួយជីវិតរបស់ព្រះនាងម៉ារី ព្រះនាងម៉ារីបានធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ពេលព្រះនាងម៉ារីបានឆ្លើយតបថាខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ គាត់បានធ្វើដំណើរមួយយ៉ាងអស្ចារ្យខុសពីធម្មតាពិតមែន ដោយសារនៅក្នុងផ្ទៃពោះរបស់ព្រះនាងមានព្រះយេស៊ូផ្ទាល់ ប៉ុន្តែអស់មួយជីវិតព្រះនាងម៉ារីបានធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ យើងត្រូវតែចូលរួមនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតមួយយ៉ាងពិសេស។

ថ្ងៃនេះព្រះសហាគមន៍ឲ្យយើងស្តាប់ ផ្លូវនៃសុភមង្គល ធម្មទេសនាទីមួយរបស់ព្រះយេស៊ូគឺណែនាំឲ្យយើងយល់អំពីគោលដៅរបស់ព្រះអង្គទៅជាអ្នកដ៏វិសុទ្ធដូចព្រះអង្គ ប៉ុន្តែតើយើងធ្វើយ៉ាងណាដើម្បីទៅដល់? ជីវិតរបស់យើងត្រូវការមានគំរូ ដើម្បីទៅមុខនៅក្នុងជីវិតរបស់យើងជាអ្នកដែឡកំពុងធ្វើដមណើរដើម្បីទៅដល់ជីវិតជាសន្តសន្តីបុគ្គល។ ថ្ងៃនេះព្រះយេស៊ូបានឲ្យសោមួយដើម្បីចូលផ្លូវនៃជីវិតសម្រាប់យើងជាគ្រីស្តបរិស័ទ ប៉ុន្តែដើម្បីបំពេញគោលដៅរបស់យើងទៅជាអ្នកដ៏វិសុទ្ធ។

**អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ** សន្តប្រាំងស្វ័រនៃទីក្រុងអាស៊ីស៊ី គាត់ជាកូនអ្នកមានគាត់បានអនុវត្តនៅក្នុងជីវិតរបស់គាត់ អំពីអត្ថន័យអ្នកណាដាក់ចិត្តជាអ្នក

ក្រខ្សត់យ៉ាងជាក់ស្តែង។ នៅថ្ងៃដែលគាត់បានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូដែលត្រាស់ហៅគាត់ ដើម្បីឲ្យគាត់កសាងព្រះសហគមន៍សាជាថ្មី។ គាត់យល់ថាជីវិតរបស់គាត់ដែលមានអ្វីៗទាំងអស់ ថ្ងៃនោះគាត់សុខចិត្តចេញពីផ្ទះរបស់គាត់ទៅផ្សារ ហើយហែកអាវរបស់គាត់ចេញនៅខ្លួនទទេ និងគាត់យកទ្រព្យសម្បត្តិរបស់ឪពុកគាត់ ចែកជាមួយអ្នកក្រីក្រទាំងអស់។ ដូចព្រះយេស៊ូបាននិយាយ "**ប្រសិនបើយើងចង់បានទទួលជីវិតអស់កល្បជានិច្ច ត្រូវលក់ទ្រព្យសម្បត្តិទាំងអស់ចែកទៅអ្នកក្រីក្រហើយដើរតាមខ្ញុំចុះ**" នេះជាអ្វីដែលសន្តហ្វ្រង់ស្វ័របានធ្វើ។ សម្ភារៈនិយមឆ្ងាយពីលោកីយ៍ ដាក់ចិត្តជាអ្នកក្រីក្រ លះបង់ចោលអ្វីៗទាំងអស់ដើម្បីទីពឹងទៅលើព្រះជាម្ចាស់ទាំងស្រុង ដោយដឹងថាព្រះជាម្ចាស់ប្រទានអ្វីៗទាំងអស់ឲ្យគាត់រស់នៅ ដើម្បីប្រកាសដំណឹងល្អនៅក្នុងជីវិតសាមញ្ញធម្មតារបស់គាត់។ សន្តហ្វ្រង់ស្វ័រ នៃទីក្រុងអាស៊ីស៊ីជាគំរូយ៉ាងពិសេស ដើម្បីឲ្យយើងរស់នៅនិងចាប់ផ្តើមធ្វើដំណើរជាអ្នកក្រខ្សត់។

**អ្នកណាសោកសៅ អ្នកនោះមានសុភមង្គលហើយ** សន្តីម៉ូនីកាបានយំច្រើនណាស់ដោយសារកូនគាត់អូហ្គូតាំង ដែលរកមិនឃើញផ្លូវសម្រាប់ជីវិតរបស់គាត់។ សន្តិម៉ូនីកា បានយំនិងទូលអង្វរដើម្បីឲ្យកូនគាត់កែប្រែចិត្តគំនិត និងរកឃើញជីវិតយ៉ាងពិសេសជាមួយព្រះជាម្ចាស់។ អូហ្គូតាំង គាត់បានដើរតាមទស្សនវិជ្ជាផ្សេងៗ ដើរតាមអសាសនា រហូតដល់ថ្ងៃមួយព្រះជាម្ចាស់បានស្តាប់សម្រែកទូលអង្វរនិងទឹកភ្នែករបស់សន្តីម៉ូនីកាដែលជាម្តាយគាត់ នៅពេលនោះបានកែប្រែចិត្តគំនិតឲ្យគាត់យល់ថា ជិត៣០ឆ្នាំដែលខ្ញុំរកមិនឃើញព្រះជាម្ចាស់ ប៉ុន្តែថ្ងៃនេះខ្ញុំយល់ហើយព្រះជាម្ចាស់មិនមែននៅក្នុងសៀវភៅ មិនមែននៅក្នុងទស្សនៈណាមួយ ព្រះជាម្ចាស់គង់នៅជាមួយខ្ញុំពីដើមរៀងមកតែខ្ញុំមិនដឹង។ ក្រោយមក គាត់ក្លាយទៅជាលោកអភិបាលយ៉ាងពិសេស ដែលបានយកចិត្តទុកដាក់ណែនាំគ្រីស្តបរិស័ទនៅទ្វីបអាហ្វ្រិក គាត់បានសរសេរសៀវភៅរាប់ពាន់ក្បាល ដែលសព្វថ្ងៃព្រះសហគមន៍បានយកទស្សនៈរបស់គាត់យកមករិះគិត។ ទាំងអស់នេះចេញពីទឹកភ្នែករបស់សន្តីម៉ូនីកា ដែលបានទូលអង្វរព្រះជាម្ចាស់ ឲ្យកូនគាត់ឈប់វង្វេងដើម្បីដើរតាមព្រះជាម្ចាស់ និងព្រះជាម្ចាស់បានស្តាប់។

**អ្នកណាស្រេកឃ្លានសេចក្តីសុចរិត អ្នកនោះមានសុភមង្គលហើយ** សន្តអូស្កាម៉ូហេរ៉ូ ជាលោកអភិបាលម្នាក់ ដែលបានយកចិត្តទុកដាក់ដើម្បីការពារអ្នកក្រីក្រនៅក្នុងប្រទេសគាត់ ដែលបានទទួលរងដោយភាពអយុត្តិធម៌ជាច្រើន។ អ្នកមានជិះជាន់អ្នកក្រីក្រ រហូតដល់គេសម្លាប់គាត់ដោយសារគេអន់ចិត្តក្នុងការស្តាប់សម្លេងរបស់គាត់ ដែលរិះគន់អ្នកដែលធ្វើបាបដល់អ្នកតូចតាចៗ។ ពីរសប្តាហ៍មុនសម្តេចប៉ាបបានទទួលស្គាល់គាត់ជាសន្តថ្មីមួយ ដើម្បីធ្វើជាគំរូនៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោកកុំឲ្យយើងខ្លាចនៅពេលយើងឃើញភាពអយុត្តិធម៌ យើងធ្វើ

យ៉ាងណាស្រែក ដើម្បីណែនាំឲ្យមនុស្សដែលទទួលរងគ្រោះ រស់នៅក្នុងសេចក្តីសុខនិងអាចមានតម្លៃថ្លៃថ្នូរ។

**អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គលហើយ** សន្តវ៉ាំសង់ឌីប៉ូលដែលរស់នៅក្នុងសតវត្សរ៍ ទី១៧ ដែលសង្គមមិនទាន់អភិវឌ្ឍន៍សោះ មានគេស្លាប់ច្រើនដោយសារជំងឺ។ សន្តវ៉ាំសង់ឌីប៉ូល ជាមិត្តភ័ក្តិអ្នកមាន គាត់បានបង្កើតកម្មវិធីយ៉ាងច្រើនដើម្បីជួយអ្នកក្រីក្រ ដើម្បីជួយអ្នកជំងឺ ដោយណែនាំឲ្យអ្នកមានចេះបម្រើអ្នកក្រីក្រ។ រហូតដល់សព្វថ្ងៃយើងមានក្រុមសន្តវ៉ាំសង់ឌីប៉ូល ដែលបង្ហាញអំពីធម៌មេត្តាករុណានៅក្នុងភូមិភាគភ្នំពេញ។ មានស្ត្រីម្នាក់កំពុងអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្ត និងមានអ្នកសុំទានម្នាក់ដែលមកសុំគាត់ឲ្យជួយ ក្រោយមកគាត់ទៅសួរសន្តវ៉ាំសង់ឌីប៉ូល លោកឪពុកតើខ្ញុំត្រូវជួយគាត់ឬខ្ញុំនៅបន្តអធិដ្ឋាន? សន្តវ៉ាំសង់ឌីប៉ូល ឆ្លើយថា ដូចគ្នាយើងកំពុងអធិដ្ឋានជាមួយព្រះយេស៊ូ យើងទៅជួយអ្នកនោះដែលកំពុងមានទុក្ខលំបាក គឺព្រះយេស៊ូដូចគ្នា។

**អ្នកណាកសាងសុខសន្តិភាព អ្នកនោះមានសុភមង្គលហើយ** សន្តយ៉ូហានប៉ូលទី២ សន្តប៉ោឡូទី៦ និងសន្តយ៉ូហានទី២៣ ទាំងបីនាក់ជាសម្តេចប៉ាប។ សន្តយ៉ូហានទី២៣ ជាសន្តដែលបានបើកមហាសន្និបាតវ៉ាទីកង់ទី២ សារលិខិតចុងក្រោយដែលគាត់បានសរសេរនៅពេលគាត់ជិតស្លាប់ គាត់បានសរសេរដើម្បីទូលអង្វរឲ្យមានសុខសន្តិភាពនៅក្នុងពិភពលោកទាំងមូល មិនមែនសម្រាប់តែគ្រីស្តបរិស័ទ គឺសម្រាប់មនុស្សទាំងអស់នៅក្នុងពិភពលោក ឲ្យយើងភ្ញាក់ស្មារតី ឲ្យយើងបញ្ចប់ការស្អប់គ្នា ឲ្យយើងបញ្ចប់សង្គ្រាម។ ពីរសប្តាហ៍មុន នៅពេលសម្តេចប៉ាបបានតែងតាំងសន្តសន្តីថ្មីៗ ក្នុងនោះមានសន្តប៉ោឡូទី៦ ដែលបានបន្តសន្តយ៉ូហានទី២៣ ដែលបានបញ្ចប់មហាសន្និបាតវ៉ាទីកង់ទី២ និងជាសម្តេចប៉ាបទីមួយដែលបានចាប់ផ្តើមធ្វើដំណើរ ប្រទេសទេមួយដែលគាត់បានទៅគឺប្រទេសអ៊ីស្រាអែល ប្រទេសរបស់ព្រះយេស៊ូ។ ទីក្រុងយេរូសាឡឹមដែលជានិមិត្តរូបនៃទីក្រុងទាំងឡាយ ជាទីក្រុងដែលភ្ជាប់ជាមួយស្ថានបរមសុខ ប៉ុន្តែជាទីក្រុងដែលពោរពេញដោយសង្គ្រាមរហូតដល់សព្វថ្ងៃ ជាទីក្រុងដែលពោរពេញដោយឈាម។ ជាទីក្រុងដែលគាត់បានជ្រើសរើស ដើម្បីប្រកាសអំពីសុខសន្តិភាពដែលពិភពលោកត្រូវតែមាន។ សន្តយ៉ូហានប៉ូលទី២ ជាសន្តពិសេសដែលបានដើរជុំវិញពិភពលោក ប្រទេសទីមួយដែលគាត់បានទៅក្នុងនាមជាសម្តេចប៉ាប គឺប្រទេសមិចស៊ិចកូ ដែលកំពុងមានបញ្ហាយ៉ាងច្រើនរវៀងអ្នកក្រីក្រនឹងអ្នកមាន នៅពេលនោះគាត់បានជួបជាមួយមហាជនយ៉ាងច្រើន ពេលសម្តេចប៉ាបទេសនា រដ្ឋាភិបាលគេបានបិទឧបករណ៍បំពងសម្លេង ដោយសារគេមិនចង់ឲ្យប្រជាជនស្តាប់អ្វីដែលសម្តេចប៉ាបនិយាយ។ ក្រោយមកអ្នកក្រីក្រគេឡើងទៅថើបសម្តេចប៉ាបដែលបង្ហាញថានេះជាសញ្ញាសម្គាល់នៃសេចក្តីសុខ។ លើកទីពីរគឺប្រទេសកំណើតរបស់គាត់ផ្ទាល់ គឺប្រទេសប៉ូឡូញ ដែល

ពោរពេញដោយកុំមុយនីស្ត ដែលបានបិទសិទ្ធិសេរីភាពរបស់ប្រជាជន ជិះជាន់ប្រជាជន ដែលណែនាំឲ្យបាត់បង់សុខសន្តិភាព។ នៅពេលគាត់ចូលនៅក្នុងប្រទេសប៉ូឡូញ មានមហាជនជាច្រើនបានមកព្រោះគាត់ទៅជាសញ្ញាសម្គាល់នៃសុភមង្គល ដោយសារគេយល់ថាគេមានសម្តេចប៉ាបដែលមកពីប្រទេសគេផ្ទាល់ មានតែគាត់ដែលអាចណែនាំឲ្យកុំមុយនីស្តធ្លាក់ចុះ ដើម្បីឲ្យគេមានសិទ្ធិសេរីភាពវិញ។ ពិតមែន ប៉ុន្មានឆ្នាំក្រោយមកកុំមុយនីស្តបានដួលរលំ ណែនាំឲ្យប្រទេសប៉ូឡូញ រុស្ស៊ី អាល្លឺម៉ង់ខាងត្បូង និងប្រទេសផ្សេងទៀតបានទទួលសិទ្ធិសេរីភាពនិងមានសេចក្តីសុខសាន្ត ដោយសារសន្តយ៉ូហានប៉ូលទី២ ដែលបានចាប់ផ្តើម។ អស់មួយជីវិតគាត់បានដើរពីប្រទេសមួយទៅប្រទេសមួយ ដើម្បីស្រែកឲ្យបញ្ចប់សង្គ្រាម ឲ្យបញ្ចប់ការស្អប់គ្នា ដើម្បីបង្កើតពិភពថ្មី។ លោកក៏បានបង្កើតទិវាយុវជនពិភពលោក ដើម្បីឲ្យយុវជនយុវនារីទៅជាទូតនៃសុខសន្តិភាព រហូតដល់សព្វថ្ងៃឲ្យយើងមានកម្លាំងកម្លាំងចិត្ត ដើម្បីរស់នៅនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

**អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ** សន្តីតេរេសានៃព្រះកុមារយេស៊ូ ជាយុវនារីធម្មតា គាត់ភ្ជាប់ជាមួយព្រះយេស៊ូតាំងពីគាត់នៅក្មេង គាត់ទន្ទឹងរង់ចាំទទួលព្រះកាយព្រះគ្រីស្ត ក្រោយមកគាត់ចេះតែគិតចង់ធ្វើជាអ្នកបួស គាត់បានធ្វើដំណើរជាមួយឪពុកគាត់ទៅទីក្រុងរ៉ូម គាត់បានសុំសម្តេចប៉ាបផ្ទាល់ដើម្បីសុំចូលអារាមកាម៉ែល ពេលគាត់អាយុ១៥ឆ្នាំគាត់បានចូលធ្វើជាបងស្រីនៅក្នុងអារាម និងរស់នៅក្នុងរបៀបសាមញ្ញធម្មតា។ យើងនឹកឃើញដល់ផ្កាកូឡាប នឹកឃើញដល់ធម្មជាតិ នឹកឃើញដល់រូបដែលគាត់បានគូរ នឹកឃើញដល់កំណាព្យដែលគាត់បានសរសេរ នឹកឃើញដល់រឿងល្ខោនដែលគាត់បាននិពន្ធ នៅក្នុងចិត្តបរិសុទ្ធ នៅក្នុងចិត្តស្រឡាញ់ នៅក្នុងចិត្តបម្រើ នៅក្នុងចិត្តដាក់ខ្លួនដើម្បីឲ្យបងស្រីដទៃមានសុភមង្គល រហូតដល់គាត់ស្លាប់នៅអាយុ២៥ឆ្នាំ។

**អ្នកដែលត្រូវគេបៀតបៀន អ្នកនោះមានសុភមង្គលហើយ** យើងនឹកឃើញដល់មរណសាក្សីទាំងឡាយនៅក្នុងពិភពលោកទាំងមូល ជាពិសេសមរណសាក្សីខ្មែរដែលជាកម្លាំងមួយអស្ចារ្យសម្រាប់ព្រះសហគមន៍យើង។ យើងមានគ្រីស្តបរិស័ទ ដែលបានសុខចិត្តទទួលការបៀតបៀននៅក្នុងជំនឿរបស់គេ ដើម្បីឲ្យព្រះសហគមន៍មានជីវិតដល់ថ្ងៃនេះ។

យើងមានគំរូមួយចំនួននៅក្នុងខ្លួនរបស់យើង ពេលទៅវិញយើងអាចពិនិត្យមើលប្រវត្តិរបស់សន្តសន្តីខាងលើ ដើម្បីចូលនៅក្នុងជីវិតដ៏អស្ចារ្យដោយសារយើងត្រូវការមានគំរូដើម្បីទៅមុខ។ យប់នេះ នៅពេលយើងនៅមុខព្រះយេស៊ូ នៅពេលយើងគោរពព្រះកាយព្រះគ្រីស្ត នេះជាគំរូដល់កំពូលដោយសារព្រះយេស៊ូជាព្រះដ៏វិសុទ្ធ ដែលយាងមកដើម្បីឲ្យយើងទាំងអស់អាចឆ្លងភាពដ៏វិសុទ្ធបាន។ ដូចពេលព្រះយេស៊ូបានជួបជាមួយមនុស្សឃ្លង់ដែលជាមនុស្សមិនបរិសុទ្ធ

ព្រះអង្គបានប៉ះគាត់ហើយមិនមែនជាព្រះយេស៊ូដែលឆ្លងជំងឺឃ្លង់ តែជាអ្នកជំងឺឃ្លង់ដែលបានជាសះស្បើយដោយសារគាត់បានឆ្លងភាពដ៏វិសុទ្ធពីព្រះយេស៊ូ។ នៅពេលយើងអង្គុយស្ងៀមស្ងាត់ដើម្បីអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្ត ឲ្យយើងទាំងអស់ឆ្លងភាពដ៏វិសុទ្ធពីព្រះយេស៊ូ ដើម្បីរស់នៅក្នុងសង្គមនៅថ្ងៃស្អែក។ អាម៉ែន៕